# ទស្សនាវដ្តីសាមគ្គី

ស៊ីហា 2011 – លើកដំបូង **1**

*សាលាសហគមន៍គ្រីស្ទបរិស័ទភូមិរូង*



អង្គការ Missione Possibile Cambodia ឆ្នាំនេះបានមានគំរោងថ្មីមួយគឺបង្កើតឲ្យមានទស្សនាវដ្តីសាលារៀន។យើងមកទីនេះដើម្បីបង្រៀនក្មេងៗអំពីការធ្វើសែត និងទស្សនាវដ្តីសាលារៀន។ គោលបំណងដើម្បីផ្តល់ពត៌មានអំពីអ្វីដែលកើតមាននៅខាងក្នុង និងខាងក្រៅសាលា។ នេះគឺជាលើកដំបូងបង្អស់ហើយ ដែលមានគំរោងនេះហើយយើងក៏នឹងមានគំរោងផ្សេងៗទៀតនៅថ្ងៃអនាគតផងដែរ។ លើសពីនេះយើងទាំងអស់គ្នាសូមថ្លែងអំណរអគុណយ៉ាងជ្រាលជ្រៅដល់លោកយាយហ្វ្រែនសិស្កា (Francesca) លោកនាយក គឹមនឿន ដែលមានគំនិតផ្តួចផ្តើមឲ្យមានសកម្មភាពនេះឡើង ហើយក៏សូមអគុណដល់លោកគ្រូដែលបានជួយធ្វើគំរោងនេះរួមមានដូចជា លោកគ្រូ វិសុទ្ធ លោកគ្រូវិបុល អ្នកគ្រូចិន្តា និងលោកគ្រូផានិត្យ។

Mr Lorenzo  Mr Matteo



សិស្សថ្នាក់ទី៤ ក លោកគ្រូផានិត្យ



សិស្សថ្នាក់ទី៤ ខ អ្នកគ្រូចិន្តា














# អគ្គិសនី






ក្នុងការរស់នៅប្រចាំថ្ងៃមនុស្សយើងតែត្រូវការភ្លើងជាចាំបាច់ដើម្បីប្រើប្រាស់។
ក្នុងនោះអណគញគ្គិសនីអាចផ្តល់ផលប្រយោជន៍យ៉ាងច្រើនតាមតំរូវការរបស់មនុស្ស។
នៅក្នុងភូមិរបស់ខ្ញុំ ចតរន្តអគ្គិសនីបានតភ្ជាប់នៅក្នុងចខែធ្នូ ឆ្នាំ២០១០ ពេលមាន
អគ្គិសនីប្រជាជនក្នុងភូមិឈប់ប្រើប្រាស់ចង្កៀងប្រេងកាត ទាន អាគុយទៀតហើយ
ហើយនាំគ្នាមកប្រើប្រាស់អំពូលភ្លើង និងទូរទស្សន៍ ដោយចរន្តអគ្គិសនីវិញ
កាលពីមិនទាន់មានភ្លើងអគ្គិសនីមកដល់ប្រជាចនមានផលលំបាកច្រើនដែលត្រូវរកលុយ
ទិញអាគុយ ដាំបាយដោយប្រើអុសរឺធ្យូង មិនបានរៀនកុំព្យូទ័រ ហើយ
មានភ្លើងមិនគ្រប់គ្រាន់តាមតំរូវការ។ ឯនៅសាលារៀនក៏មានការផ្លាស់ប្តូរច្រើន
ដោយមានកុំព្យូទ័រតាមបន្ទប់មានភ្លើងបំភ្លឺ(អាចរៀនបន្ថែមពេលយប់) ហើយ
តាមថ្នាក់នីមួយៗមានព្រីសំរាប់ដោតភ្លើងប្រើប្រាស់ផ្សេងៗ។ ចំនែកនៅតាមផ្ទះ
មានភាពងាយស្រួលច្រើនដោយមានភ្លើងបំភ្លឺគ្រប់គ្រាន់ យើងអាចប្រើកង្ហារ
ឆ្នាំងដាំបាយនិងឆ្នាំងអ៊ុតអគ្គិសនី និង ឧបករណ៍ផ្សេងៗទៀតបាន។ ម្យ៉ាងវិញ
ទៀតយើងអាចប្រកបមុខរបរដទៃទៀត តាមរយៈចរន្តអគ្គិសនី។
ប៉ុន្តែដោយអគ្គិសនីមានមិនគ្រប់គ្រាន់ និងតំលៃថ្លៃធ្វើអោយគ្រួសារខ្ញុំមានការលំ
បាកដោយត្រូវចំនាយលុយច្រើន ក្នុងការបង់ថ្លៃភ្លើង។
នៅថ្ងៃខាងមុខខ្ញុំចង់អោយមានភ្លើងទៀងទាត់គ្រប់ពេលវេលា និងមានតំលៃថោកជាង
មុនដើម្បីអោយមនុស្សគ្រប់គ្នាមានលទ្ធភាពប្រើប្រាស់ភ្លើងបានគ្រប់គ្នា ពេលនោះ
យើងអាចប្រើប្រាស់កុំព្យូទ័រ ធុងបាស់ ក្បាលCDVCD ទូទរស្សន៍ពណ៌.....
តាមតំរូវការ។

សៀកហុង   វេហា   ណន   ធារី   ភីអូន   រដ្ឋា   ស្រីអេង

# សត្វពាហៈណៈ




នៅក្នុងប្រទេសកម្ពុជាប្រជាជនដែលរស់នៅតាមជនបទភាគច្រើនប្រកបរបចិញ្ចឹមជីវិតដោយធ្វើ
ស្រែនិងចញ្ចឹមសត្វ។

សត្វពាហៈណៈដែលប្រជាជនចិញ្ចឹមមានដូចជា៖គោ ឆ្កែ ជ្រូក សេះ ក្របី ដំរី មាន់ ទា ឆ្មា។សត្វ
ទាំងអស់នេះគឺជាសត្វដែលប្រជាជនចូលចិត្តចិញ្ចឹមគ្រប់គ្នាព្រោះវាងាយស្រួលក្នុងការចញ្ចឹមហើយប្រជាជនដឹងពី
វិធីចញ្ចឹមនិងដឹងពីចំណីរបស់សត្វនីមួយៗ ដែលវាស៊ីចំណីរបស់ទាំងនោះមានដូចជា៖ចំបើង ស្មៅ បាយ កន្ទួក
ស្លឹករុក្ខជាតិផ្សេងៗ
ទៀតក្នុងការចិញ្ចឹងសត្វទាំងអស់នេះមានប្រយោជន៍ណាស់សំរាប់ជីវភាពរស់នៅរបស់ប្រេជាជនដូចជា៖ធ្វើស្រែ
ចំការ សំរាប់ធ្វើម្ហូប សំរាប់លក់ យកស៊ុត អាចម៏ទៅដាក់ស្រែ
រឺដំណាំជុំវិញផ្ទះឲ្យវាកាន់តែល្អ។បុន្តែមុននិងទទួលបានផលពីសត្វទាំងនោះគឺយើងត្រូវចំនាយដើមក្នុងការទិញចំ
ណីព្រមទាំងចំនាយពេលវេលាក្នុងការថែរក្សាវាអោយបានល្អប្រសើរ។ជាធម្មតាមនុស្សយើងក្នុងការរស់នៅគឺយើ
ងត្រូវការហូបចំនីអាហារ បាយជាមួយនិងសម្លរឺម្ហូបផ្សេងៗ  ដូចជា៖ត្រីអាំង សាច់ជ្រូក សាច់គោ សាច់មាន់
ប្រហុក
ទឹកគ្រឿង។ក្នុងចំនោមសាច់ទាំងអស់នេះយើងចូលចិត្តហូបត្រី។ត្រីគឺជាសត្វរស់នៅក្នុងទឹកដូចជា៖ដើម្បីបានត្រី
ធ្វើជាម្ហូបយើងត្រូវទៅរកវានៅតាមបឹង ព្រែក ស្ទឹង
រឺត្រពាំងនានានៅក្នុងភូមិ។មនុស្សយើងរស់នៅបានអាស្រ័យដោយមានចំនីអាហាររីឯសត្វក៏ដូចមនុស្សយើងដែរគឺ
វាក៏ត្រូវការចំនីអាហារដែរ។

សរុបមកសត្វទាំងអស់នេះខ្ញុំចូលចិត្តចិញ្ចឹមវានៅក្នុងគ្រួសារណាស់ព្រោះវាបានផ្តល់ផល
ប្រយោជន៍ជាច្រើនសំរាប់គ្រួសារខ្ញុំ។ដូចនេះខ្ញុំត្រូវខិតខំថែរក្សាទាំងអស់នោះឲ្យបានល្អ។

ណុបពុទ្ធី គឹមម៉េងគី សែនគន្ធី ទូច ស្រីនិច

# រោងចក្រ




នៅក្នុងប្រទេសកម្ពុជាមានរោងចក្រច្រើនណាស់ប៉ុន្តែយើងឃើញរោងចក្រដែលគេកំពុងសាងសង់ឋិតនៅក្នុងភូមិរូងឃុំក្រាំងលាវស្រុកបាទីខេត្តតាកែវ។

គេសាងសង់អគាររោងចក្រនៅខាងលិចថ្នល់ផ្លូវជាតិលេខ៣មនុស្សជិតឆ្ងាយរីនៅក្នុងភូមិនោះបានមកធ្វើការនៅក្នុងរោងចក្រនេះយ៉ាងមានទឹកមុខរីករាយពួកគេម្នាក់ៗគិតក្នុងចិត្តថានិងបានប្រាក់មកជួយសម្រួលជីវភាពក្នុងគ្រួសាររបស់ពួកគេ។ ការងារដែលពួកគេធ្វើមានច្រើនប្រភេទណាស់ដូចជា ដេរខោអាវ ដេរស៊ីឡូ ដេរស្បែកជើង ដេរម្ជូក និងប្រធានរោងចក្រ។ឯអ្នកភូមិជិតនោះគេអាចធ្វើការលក់ដូរដូចជា លក់កាហ្វេ លក់ស្រា លក់កាទាវ លក់សម្លរ លក់ទឹកបរិសុទ្ធ លក់បាយ និងធ្វើផ្ទះជួល។ពួកដែលធ្វើការទាំងអស់ក្នុងរោងចក្រពួកគេតែងតែហូបអាហារថ្ងៃត្រង់នៅមុខរោងចក្ររីឯក្នុងភូមិនោះអាចមានជីវភាពល្អប្រសើរជាងមុន។ចំនែកថ្នល់ជាតិដែលនៅជិតរោងចក្រនោះរឹតតែមានឡានម៉ូតូជាច្រើនដែលបានធ្វើដំណើរ។

ប៉ុន្តែយើងទាំងអស់គ្នាវិញមិនចង់ធ្វើការក្នុងរោងចក្រនោះទេពីព្រោះវាពិបាក ច្រើនណាស់បញ្ហាទាំងនោះមានដូចជាពុលក្រណាត់ ប្រាក់ខែតិច ហត់នឿយ អត់ងងុយនិងអាចធ្វើ អោយយើងខូច សុខ ភាព គ្រប់ៗ គ្នា។យើងទាំងអស់គ្នាគិតថារោងចក្រនេះនិងរឹតតែល្អប្រសើរជាងនេះទៅទៀតឯអ្នកនៅជិតនោះរឹតតែមានការងារជាងមុនហើយនិងមានជីវភាពធូធាជាងមុន។

ម៉ៅ សៀកឡាំង ឡៅ ចន្ធី សួង វិសា អ៊ុំ សុភ័ក្ត្រនាថ
ទូច ស្រីណែត លឹម ស្រីដា

# បណ្ណាល័យ




នៅក្នុងសាលារៀនណាក៏ដូចជាសាលារៀនណាដែរតែងតែមានឯកសារឬសៀវភៅរឿងផ្សេងៗជាច្រើនសំរាប់ទុកឲ្យសិស្សានុសិស្សឬលោកគ្រូអ្នកគ្រូចូលអានដូចនេះដើម្បីរក្សាទុកឯកសាទាំងអស់នោះគឺយើងត្រូវសាងសង់បណ្ណាល័យ។

បណ្ណាល័យមានតាំងពីដើមឆ្នាំ២០១០មកម្លេះហើយបណ្ណាល័យវាមានប្រយោជន៍ណាស់គឺសំរាប់ទុកឯកសាផ្សេងៗដើម្បីឲ្យសិស្សចូលស្រាវជ្រាវនឹងអានសៀវភៅផ្សេងៗ។ម្យ៉ាងទៀតនៅក្នុងបណ្ណាល័យមិនមែនមានតែសៀវភៅរឿងភាសាខ្មែរទេគឺវាមានសៀវភៅច្រើនប្រភេទទៀតដូចជាសៀវភៅរឿងភាសាអង់គ្លេស សៀវដំណាំ សៀវភៅចិញ្ចឹមសត្វថែមទាំងមានរូបភាពសំរាប់ឲ្យសិស្សរៀនរៀបទៀតផងហើយខ្ញុំគិតថានៅក្នុងបណ្ណាល័យមានសៀវភៅ៦៩៧ក្បាលហើយក៏មានគំរោងទិញសៀវភៅបន្ថែមទៀតដូចជាសៀវភៅរឿងអមដោយរូបភាព សៀវភៅរូបភាព និងសៀវភៅរឿងភាសាអង់គ្លេសលាយខ្មែរ។ខ្ញុំចូលចិត្តអានសៀវភៅទាំងនោះណាស់ព្រោះវាធ្វើឲ្យខ្ញុំដឹងពីរឿងអ្វីដែលទាក់ទងនឹងសៀវភៅនោះរីឯសំរាប់អ្នកភូមិខាងក្រៅដើម្បីចូលបណ្ណាល័យបានតាមរយៈការអញ្ជើញរបស់អង្គការផ្សេងៗមកបង្រៀននិងជួយសំរួលដល់បញ្ហាផ្សេងៗសំរាប់ប្រជាជននៅក្នុងភូមិរូងដូចជា៖ អញ្ជើញប្រជាជនក្នុងភូមិឲ្យចូលរួមក្នុងបណ្ណាល័យឬបង្កើតឲ្យមានសកម្មភាពផ្សេងៗទៀត។ ប្រធានបទសំរាប់ការបង្រៀនរួមមានដូចជា៖ ការលើកទឹកចិត្ត បញ្ហាទឹកស្អាតនឹងអនាម័យ សមពាពរវាងបុរសនឹងស្ត្រីសុភមង្គលក្នុងគ្រួសានឹងមានកាបញ្ជាំងភាពយន្តជាដើម។ចំនែកឯការជួបជុំគ្នាក្នុងបណ្ណាល័យមានគោលបំណងដើម្បីពង្រីកការយល់ដឹងដល់ប្រជាជនក្នុងភូមិម្យ៉ាងទៀតដើម្បីបង្កើតឲ្យមានទំនាក់ទំនងល្អរវាងប្រជាជនក្នុងភូមិនិងដើម្បីជួយសំរួលក្នុងការស្វែងរកដំណោះស្រាយលើបញ្ហាផ្សេងដែលមានក្នុងភូមិ។អ្នកដែលរៀបចំការងារនេះគឺលោកគ្រូ ពិសិដ្ឋ។

ខ្ញុំមានចំណាប់អារម្មណ៍ណាស់សំរាប់ការរៀបចំបណ្ណាល័យនេះណាស់ព្រោះបណ្ណាល័យគឺជាបន្ទប់ដាក់សៀវភៅរឿងទុកឲ្យសិស្សអានវា។អញ្ចឹងហើយយើងគួតែថែរក្សាការពារកុំឲ្យបណ្ណាល័យនេះបាត់បង់ឲ្យសោះ។

ឈ្មោះ វ៉ាន់ ឈុន . បុល ថង . រិត សីថុល . រឿន សុខមាន.

# ដំណាំ





ដំគឺជារុក្ខជាតិ ដែលត្រូវការយកមកបរិភោគជារៀងរាល់ថ្ងៃ ប៉ុន្តែដំណាំទាំងអស់យើងអាចបរិភោគខុសៗ គ្នា។ដំណាំខ្លះផ្លែទុំទើបយើងអាចបរិភោគបាន ដំណាំខ្លះទៀតឆ្អិនទើបយើងអាចបរិភោគបាន។

ប្រភេទដំណាំដែលទុំទើបយើងអាចបរិភោគបានមានដូចជា ផ្លែមៀន ផ្លែសាវម៉ៅ ស្រូវ ម្នុត ព្រីង ផ្លែទឹកដោះ...។ រីឯ ដំណាំដែលឆ្អិនទើបយើងអាចបរិភោគបានមានដូចជា ពោត ស្ពៃ ត្រលាច ននោង ស្លឹកបាស ដំលូង ស្លឹកងប់ ឆៃថាវ ត្រពាំង ស្លឹកម្រុំ...។ ប៉ុន្តែដំណាំដែលសំខាន់ជាងគេនៅក្នុងប្រទេសកម្ពុជាគឺ ស្រូវ។ ព្រោះមនុស្សគ្រប់ គ្នារស់បាននៅក៏ដោយសារតែអង្ករ ម្យ៉ាងទៀតអង្ករមិនត្រឹមតែសំរាប់ហូបទេគឺ គេអាចវាទៅលក់នៅតាមទីផ្សារ។ ដំណាំស្រូវគេអាចធ្វើក្នុងមួយឆ្នាំ១ទៅ២ដង អាស្រ័យទៅលើទឹក។ ប៉ុន្តែអ្នកខ្លះយកដីរបស់គេទៅដាំដំណាំផ្សេងៗពេលគេដាំបានផលគេយកវាទៅលក់ឬបរិភោគដើម្បីសំរួលជីវភាពរស់នៅរបស់គ្រួសារ។រីឯដំណាំដែលគេមិនអាចដាំបានមានច្រើនណាស់ប៉ុន្តែទោះបីដំណាំមិនទាន់ដាំបានក៏ដោយក៏គេនៅតែមានទឹកចិត្តតស៊ូព្យាយាមដាំដើម្បីឲ្យយើងចេះដាំដំណាំទាំងនោះ។

សរុបមកគ្រប់ដំណាំទាំងអស់ក្នុងប្រទេសកម្ពុជាសុទ្ធតែមានសារះប្រយោជន៏សំរាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សយើងគ្រប់ៗគ្នាដូចនេះយើងទាំងអស់គ្នាត្រូវតែខិតខំដាំដំណាំនិងថែរក្សាឲ្យបានល្អ ។

អ៊ុំ ពិសិដ្ឋ ទូច បញ្ញា វង់ សម្ភស្ស លី អ៊ីឡុង នាង ដាលីន

# សាលារៀន





មនុស្សគ្រប់រូបតែងតែត្រូវការចំនេះវិជ្ជាសំរាប់ជិវីតរស់នៅហើយចំនេះវិជ្ជាទាំងអស់បានមកពីការរៀនសូត្រនៅសាលារៀននិងទីកន្លែងផ្សេងៗទៀត។ជាក់ស្តែងដូចជាសាលាបឋមសិក្សាសហគមន៍គ្រីស្ទបរិសទ័ដែលស្ថិតនៅក្នុងភូមិរូង ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ
ត្រូវបានបង្កើតឡើងកាលពីឆ្នាំ២០០៦ដោយមានអង្គការ Missione Possibile Cambodia
ជាអ្នកឧបត្ថម្ភក្នុងការសាងសង់អាគារសិក្សានិងឧបត្ថម្ភផ្នែកផ្សេងៗទៀត។នៅក្នុងសាលានេះមានអាគារសិក្សាចំនួន៤ខ្នង់។
ពីរខ្នង់បានសាងសង់កាលពីឆ្នាំ២០០៦ហើយអាគារមួយខ្នង់ជាបន្ទប់រៀននិងមួយខ្នង់ទៀតជាការិយាល័យ បន្ទប់សំភារះផ្សេងៗនិងបន្ទប់សំរាប់ឱ្យគ្រូសំរាក(គេង)។
ហើយនៅឆ្នាំ២០០៩បានសាងសង់អាគារពីខ្នង់ទៀតដែលចែកជាប្រាំបួនបន្ទប់ក្នុងនោះផ្ទះបាយមួយបន្ទប់ បណ្ណាល័យមួយបន្ទប់ កុំព្យូទ័រមួយបន្ទប់និងបន្ទប់រៀនប្រាំមួយបន្ទប់។ សាលារៀននេះមាន១២ថ្នាក់ ថ្នាក់ទី១មានពីថ្នាក់ ថ្នាក់ទី២មានពីថ្នាក់ ថ្នាក់ទី៣មានពីថ្នាក់ ថ្នាក់ទី៤មានពីថ្នាក់ ថ្នាក់ទី៥មានពីថ្នាក់ ថ្នាក់ទី៦មានពីថ្នាក់។ ហើយសិស្សមានចំនួន៣៦០នាក់។សិស្សទាំងអស់មកពីភូមិរូង ត្រពាំងអង្គ
ត្រាចកុះ
ត្រាំត្បាល់...និងភូមិដ៏ទៃទៀត។សិស្សទាំងអស់មករៀនដោយថ្មើរជើងនិងខ្លះទៀតមករៀនដោយជិះកង់។នៅក្នុងសាលារៀននោះគ្រូបានបង្រៀនមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា សិក្សាសង្គម
វិទ្យាសាស្ត្រអនុវត្ត ភាសាអង់គ្លេស ព្រះគម្ពីរ...។គ្រូបង្រៀនមានចំនួន១៥នាក់ ស្រី៦នាក់ ប្រុស៩នាក់។

សាលារៀននេះជាសាលាដែលល្អជាងគេ
នៅក្នុងខេត្តតាកែវព្រោះសិស្សទាំងអស់ត្រូវបានទទួលការបណ្តុះបណ្តាលពីពេលព្រមទាំងមានបង្រៀនភាសាអង់គ្លេសទៀតផង ហើយសាលាបានផ្តល់អ្វីៗជាច្រើនទៀតដល់សិស្សដូចជាសំលៀកបំពាក់សំភារះសិក្សានិងរៀនកុំព្យូទ័រដោយមិនយកប្រាក់ដោយគ្រាន់តែបង់ប្រាក់ម្នាក់មួយដុល្លាក្នុងមួយខែតែប៉ុនោះ។ហើយនៅពេលខាងមុខសាលាមានគំរោងធ្វើបណ្ណាល័យនិងកុំព្យូទ័របន្ថែមទៀត។ខ្ញុំចូលចិត្តសាលារៀនណាស់ព្រោះសាលារៀនផ្តល់ចំណេះដឹងយ៉ាងច្រើនដល់មនុស្សហើយចំណេះដឹងធ្វើឱ្យមនុស្សមានអនាគតល្អមានអនាម័យ ចេះគិតពិចារណាបានវែងឆ្ងាយ គ្មានអំពើហឹង្សារក្នុងគ្រួសារ
ហើយរស់នៅដោយសេចក្តីសុខនិងសុភមង្គល។

ស្រីល័ក្ខ សុខចាន់ ស្រីតូច វណ្ណះ ពុធឈៀ ប៉ុនថេង លៀប។





# កីឡា





មនុស្សយើងគ្រប់គ្នា តែងប្រាថ្នាចង់បាននូវអ្វីដែលល្អៗសំរាប់ជីវិតរស់នៅ។ក្នុងនោះសុខភាពនិងភាពល្បីល្បាញក៏មនុស្សគ្រប់គ្នាតែងតែត្រូវការដោយមិនខានបាន។ហើយកីឡាបាល់ទាត់ក៏អាចធ្វើអោយមនុស្សមានសុខភាពល្អនិងភាពល្បីល្បាញផងដែរ។

ជាក់ស្តែងនៅក្នុងភូមិរូងឃុំក្រាំងលាវស្រុកបាទីខេត្តតាកែវបានបង្កើតទីលានបាល់ទាត់ដ៏ធំមួយហើយគេនិងបើកសម្ពោធអោយប្រើប្រាស់នៅខែកញ្ញាឆ្នាំ២០១១ខាងមុខនេះ។ទីលាននេះគេសាងសង់ឡើងកាលពីខែឧសភាឆ្នាំ២០១០។មុនពេលសាងសង់ខ្ញុំបានឃើញក្រុមអ្នកសាងសង់ដឹកដីដោយរថយន្តទៅចាក់បំពេញកន្លែងនោះ រួចហើយបានឈូសពង្រោះដីអោយស្មើបន្ទាប់មកបានកិនបង្ហាប់ យ៉ាងស្អាត។នៅក្នុងនោះក្រុមអ្នកសាងសង់បានធ្វើគោលបាល់ទាត់ ដាំស្មៅបានយ៉ាងល្អ។នៅជុំវិញទីលានគេធ្វើរបងខ្ពស់ព័ទ្ធជុំវិញដើម្បីការពារមិនឲ្យបាល់ខ្ទាត ចេញក្រៅបាន។

នៅពេលខាងមុខសិស្សទាំងអស់ប្រាកដជាបានលេងបាល់ទាត់នៅក្នុងទីលាននោះជាមិនខានហើយសិស្សសាលាដទៃទៀតសុទ្ធតែអាចមកលេងបាល់ទាត់នៅក្នុងទីលាននោះបានលើកលែងតែអ្នកភូមិបើចង់លេងត្រូវបង់ប្រាក់សំរាប់លេងកីឡាធ្វើអោយមនុស្សមានសុខភាពល្អ មានមិត្តភក្តិច្រើនមានសាមគ្គីភាពរវាងគ្នានិងគ្នាមាន កំលាំងមាំមួន មានភាពសប្បាយរីករាយដែលអាចបំបាត់ការ អផ្សុក។ប៉ុន្តែដោយសារពួកខ្ញុំមិនបានដឹងពីច្បាប់នៃការបាល់ទាត់ទេព្រោះពីមុនខ្ញុំធ្លាប់លេងបាល់ទាត់តែតាមវាលស្រែជិតៗផ្ទះ ដើម្បីតែបំបាត់ការអផ្សុកតែប៉ុននោះ។

ខ្ញុំសង្ឃឹមថានៅពេលខាងមុខនិងមានគ្រូបរទេស(អ៊ីតាលី)និងមកជួយបង្ហាត់បង្រៀនដល់គ្រូជនជាតិខ្មែរ ដើម្បីឲ្យពួកគាត់យកចំនេះដឹងទាំងនោះមកបង្ហាត់បង្រៀនពួកខ្ញុំឲ្យបានយល់ពីច្បាប់នៃការលេងបាល់ទាត់ឲ្យបានច្បាស់។

សោភា សុខណេត រាជ បញ្ញា ចន្ថា សុខអូន ចន្ទីវិន